ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚ ❖ ៚

ក្រសួងអប់រំ យុវជន និង កីឡា

លេខ : ៤០៤ អយក.ប្រក

# ប្រកាស

## ស្តីពីការបើកសាលាបឋមសិក្សា ព្រៃខ្លា

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
-បានពិនិត្យលិខិត ចុះថ្ងៃទី ១៨ ខែ ០២ ឆ្នាំ ២០០២ របស់នាយកសាលាបឋមសិក្សា ព្រៃខ្លា ដោយចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ព្រៃវែង ចុះថ្ងៃទី ២០ ខែ ០៣ ឆ្នាំ ២០០២ ។
-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សំ រេ ច

**ប្រការ១** :-បើកសាលាបឋមសិក្សា ព្រៃខ្លា ដែលមានទីតាំងស្ថិតនៅ ភូមិ ព្រៃខ្លា ឃុំ ព្រៃកណ្ដៀង ស្រុក ពាមរក៍ ខេត្ត ព្រៃវែង ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា ព្រៃកណ្ដៀង ចាប់ពីឆ្នាំសិក្សា ២០០០-២០០១ នេះតទៅ ។

**ប្រការ២** :-សាលាបឋមសិក្សា ព្រៃខ្លា ត្រូវមានប្រធានក្រុមម្នាក់ទទួលខុសត្រូវរួមជាមួយនាយកសាលាបឋមសិក្សា ព្រៃកណ្ដៀង ។

**ប្រការ៣** :-បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤** :-នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ព្រៃវែង ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក ពាមរក៍ នាយកសាលាបឋមសិក្សា ព្រៃកណ្ដៀង និង ប្រធានក្រុមសាលាឧបសម្ព័ន្ធ ព្រៃខ្លា មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ .ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០២

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

រដ្ឋលេខាធិការ

**អ៊ឹម.សិទ្ធី**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
" ដើម្បីជូនជ្រាបជាពតិមាន "
- សាលាខេត្ត ព្រៃវែង " ជូនជ្រាបជាពតិមាន "
- ដូចប្រការ ៤
- កាលប្បវត្តិ - ឯកសារ នា -ប.ម